ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តព្រៃវែង**
សំណុំរឿងរដ្ឋប្បវេណីលេខ ២២
ចុះថ្ងៃទី២៣ខែមករា ឆ្នាំ២០២០
សាលក្រម
លេខ ១២៥/៥៥ (ក)
ចុះថ្ងៃអង្គារ ៩កើត ខែមិគសិរ ឆ្នាំជូត
ទោស័ក ព.ស២៥៦៤ ត្រូវនឹងថ្ងៃ
ទី២៤ ខែវិច្ឆិកា ឆ្នាំ២០២០

# លិខិតសាលក្រម

## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តព្រៃវែង

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ និង បានធ្វើការប្រកាសសាលក្រម នាថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ៨ និង ៤០ នាទីព្រឹក ដោយមានសមាសភាពចូលរួមដូចខាងក្រោម៖

**ចៅក្រមជំនុំជម្រះ**

ឯកឧត្តម [redacted] ជាប្រធានសាលាដំបូងខេត្តព្រៃវែង

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តព្រៃវែង

បានធ្វើទាញហេតុផលដោយផ្ទាល់មាត់លើសំណុំរឿងរដ្ឋប្បវេណីលេខ២២ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០២០ រវាង៖

**ភាគី:**

-ដើមចោទឈ្មោះ [redacted] ជ័យ ភេទប្រុស អាយុ៥៦ឆ្នាំ មុខរបរចូលនិវត្តន៍ ជនជាតិខ្មែរ អាសយដ្ឋាន [redacted] មេធាវីតំណាងដោយអាណត្តិលោក [redacted]។

-ចុងចម្លើយឈ្មោះ [redacted] សំអាន ហៅនាង ភេទស្រី អាយុ៥៣ឆ្នាំ ជនជាតិខ្មែរ មុខរបរធ្វើស្រែ អាសយដ្ឋាននៅភូមិ [redacted] ដែលមានមេធាវីតំណាងដោយអាណត្តិ លោក [redacted]។

**១.អង្គហេតុ និងចំណុចវិវាទ**

១-១.ខ្លឹមសារនៃសាលក្រមដែលដើមចោទជាមជារ:

ដើមចោទបានប្ដឹងទាមទារសុំឲ្យតុលាការសម្រេចតាមខ្លឹមសាដូចខាងក្រោម៖

១.សុំផ្ដាច់ចំណងអាពាហ៍ពិពាហ៍ ពីប្រពន្ធឈ្មោះ [redacted] សំអាន ។

២.សុំបែងចែកទ្រព្យសម្បត្តិរួម ជាពីរចំណែកស្មើគ្នា រួមមាន៖

-ដីលំនៅដ្ឋាន (រស់នៅសព្វថ្ងៃ) មានទំហំ៦៣០ ម៉ែត្រការ៉េ និងមានព្រំប្រទល់ជាប់ ខាងកើតជាប់ដីឈ្មោះ [redacted] ប៊ុនណាត ខាងលិចជាប់ដីឈ្មោះ [redacted] សារុធ ខាងជើងជាប់ថ្នល់ និងខាងត្បូងមិនស្គាល់ឈ្មោះ។

ដីនេះស្ថិតនៅ[redacted] ផ្ទះ ដែលមានវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ ១២១១០៣០៨-០០៤៣ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៦ ។

- ផ្ទះឈើ១ខ្នង ប្រក់ស៊ីប្រូ ទំហំ៦ម គុណនឹង ៨ម សាងសង់ស្ថិតនៅដីលំនៅដ្ឋានខាងលើ។

-ដីលំនៅដ្ឋាន (មានបូងរីង) ទំហំ២៥ម គុណនឹង ៣០០ម (ដីទំនេរ) ស្ថិតនៅភូមិស្រែស្បូវ ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ។

-ដីភនថ្មីថ្នល់លំ (មានលិខិតបញ្ជាក់ភូមិឃុំ) ទំហំ ២៥ម គុណនឹង ៣០០ម ស្ថិតនៅភូមិស្រែស្បូវ ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ។

-ដីភនថ្មីថ្នល់លំ (មានលិខិតបញ្ជាក់ភូមិឃុំ) ទំហំ ៧៥ម គុណនឹង ៣០០ម ស្ថិតនៅភូមិស្រែស្បូវ ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ។

៣.ទាមទារបែងចែកប្រាក់ខែរបស់ខ្លួនដែលប្រពន្ធឈ្មោះ [redacted] សំអាន ជាអ្នកបើកយក និងប្រាក់ចំណូលផ្សេងៗទៀត រួមមាន៖

-ប្រាក់ខែខ្លួនគិតចាប់ពីឆ្នាំ២០១០ រហូតដល់ឆ្នាំ២០១៨ មានរយៈពេល៨ឆ្នាំ ដោយក្នុង ១ឆ្នាំ ទឹកប្រាក់គិតជាមធ្យមចំនួន២៤០០ ដុល្លាសរុបជាទឹកប្រាក់ចំនួន១៩២០០ ដុល្លា។

-ប្រាក់ចំណូលផាស៊ីម៉ូតូបានធ្វើនៅឆ្នាំ២០១៨ ទឹកប្រាក់ទទួលបានបន្ទាប់ពីការទូទាត់រួចមានចំនួន១,០០០,០០០ រៀល ក្នុង១ខែ សរុបទឹកប្រាក់ទាំងអស់ចំនួន១២,០០០,០០០ រៀល។

## ១.២.អង្គហេតុចាំបាច់

ដើមចោទនិងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍ ជាមួយគ្នាតាមប្រពៃណីជាតិ និង មាននីតិសង្វាសនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៧។ រយៈពេលចុងក្រោយនៃការរួមរស់ក្នុងចំណងអាពាហ៍ពិពាហ៍ គូភាគីតែងតែមានការមិនចុះសម្រុងដោយប្រើពាក្យសំដីអសុរស់ ដេរបណ្ដេញប្ដីឲ្យចុះចេញពីផ្ទះ និងធ្លាប់ប្ដឹងប្ដី ដែលជាហេតុធ្វើឲ្យអស់មនោសញ្ចេតនាមិនអាចរួមរស់ជាមួយគ្នាតទៅទៀតបាន។

## ១.៣.ការពន្យល់ត្រួសៗអំពីរឿងក្ដី៖

ដើមចោទនិងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍ ជាមួយគ្នាតាមប្រពៃណីជាតិ នៅភូមិកំពង់ស្វាយ ឃុំកំពង់ត្របែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ដោយបានទៅចុះសំបុត្រអាពាហ៍ពិពាហ៍លេខ



Scanned with CamScanner

១២៧ ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៧ នៅចំពោះមុខមន្ត្រីអាត្រានុកូលដ្ឋានសង្កាត់កំពង់លាវ។ រយៈពេលចុងក្រោយនៃការរួមរស់ក្នុងចំណងអាពាហ៍ពិពាហ៍គូភាគីតែងតែមានការ មិនចុះសម្រុងដោយប្រើពាក្យសំដីអសរស់ ដេរបណ្ដេញឲ្យចុះចេញពីផ្ទះ និង ធ្លាប់ប្ដឹងប្ដី ដែលជាហេតុធ្វើឲ្យអស់មនោសញ្ចេតនាមិនអាចរួចរស់ជាមួយគ្នាតទៅទៀតបាន។

១.៤.សេចក្ដីថ្លែងការណ៍របស់គូភាគីៈ

ក.សេចក្ដីថ្លែងការណ៍របស់ដើមចោទៈ

ដើមចោទឈ្មោះ [redacted] ជ័យ និង មានមេធាវីតំណាងដោយអាណត្តិ លោក [redacted] បានធ្វើការអះអាងថាៈ កាលពីថ្ងៃខែមិនចាំ ឆ្នាំ១៩៩១ រូបខ្លួនបានរៀបអាពាហ៍ពិពាហ៍ ជាមួយឈ្មោះ [redacted] សំអាន នៅភូមិកំពង់ស្វាយ ឃុំកំពង់ត្របែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង តាមប្រពៃណី ដោយបានទៅចុះសំបុត្រអាពាហ៍ពិពាហ៍លេខ ១២៧ ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៧ នៅចំពោះមុខមន្ត្រីអាត្រានុកូលដ្ឋានសង្កាត់កំពង់លាវ ចំពោះកូនគ្មាន។

ការរួមរស់ជាមួយគ្នាកន្លងមកមានការ មិនចុះសម្រុងដោយ ប្រើពាក្យសំដីអសរស់ ដេរបណ្ដេញខ្លួនឲ្យចុះចេញពីផ្ទះ និង ធ្លាប់ប្ដឹងរូបខ្លួន ដែលជាហេតុធ្វើឲ្យខ្លួនអស់មនោសញ្ចេតនាមិនអាចរួមរស់ជាមួយគ្នាតទៅទៀតបាន។

រូបខ្លួននៅតែប្ដឹងសុំផ្ដាច់ចំណងអាពាហ៍ពិពាហ៍ ពីប្រពន្ធឈ្មោះ [redacted] សំអាន ដោយឡែកទ្រព្យសម្បត្តិរួមក្នុងពាក្យបណ្ដឹងនោះ រូបខ្លួនសុំលះបង់ការទាមទារវិញ ប៉ុន្តែក្នុងពេលនេះរូបខ្លួនសុំទាមទារតែបំណុលដែលក្មួយឈ្មោះ [redacted]ធារី បានខ្ចីប្រាក់ចំនួន២.០០០.០០០ (ពីរលាន) រៀល និងប្អូនឈ្មោះ [redacted] លន់ បានខ្ចីប្រាក់ចំនួន៧០០.០០០ (ចិតសិបម៉ឺន) រៀល ដែលជាទ្រព្យសម្បត្តិរួមរបស់ពួកខ្លួននោះ រូបខ្លួនសុំធ្វើការទាមទារ និង សុំទាមទារប្រាក់ពីចុងចម្លើយបន្ថែមចំនួន ៥០០$ (ប្រាំរយដុល្លា) ទឹកប្រាក់នេះប្រគល់ឱ្យមករូបខ្លួន នៅពេលសាលក្រមចូលជាស្ថាពរ ។ដីលំនៅដ្ឋាន (រស់នៅសព្វថ្ងៃ) មានទំហំ៦៣០ម៉ែត្រការ៉េ និងមានព្រំប្រទល់ជាប់ ខាងកើតជាប់ដីឈ្មោះ [redacted] ប៊ុនណាត ខាងលិចជាប់ដីឈ្មោះ [redacted]សារ៉ុជ ខាងជើងជាប់ថ្នល់ និងខាងត្បូងមិនស្គាល់ឈ្មោះ។

ដីនេះស្ថិតនៅភូមិ០៨ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង ផ្ទះ ដែលមានវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ ១៤១១០៣០៨-០០៤៣ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៦ ។

-ផ្ទះឈើ១ខ្នង ប្រក់ស៊ីប្រូ ទំហំ៦ម គុណនឹង ៨ម សាងសង់ស្ថិតនៅដីលំនៅដ្ឋានខាងលើ រូបខ្លួនឯកភាពឱ្យទៅចុងចម្លើយជាអ្នកកាន់កាប់ធ្វើជាកម្មសិទ្ធិ ។

ចំពោះដីលំនៅដ្ឋាន ទំហំ២៧០៥ម៉ែត្រការ៉េ ស្ថិតនៅភូមិស្រែស្បូវ ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ វិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ ១០០៤០៣០៤-០០៩៣ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៤



Scanned with CamScanner

របស់មន្ទីររៀបចំដែនដីនគររូបនីយកម្ម សំណង់ និងសុរិយោដីខេត្តក្រចេះ រូបខ្លួនឯកភាពឱ្យទៅចុងចម្លើយជាអ្នកកាន់កាប់ធ្វើជាកម្មសិទ្ធិ ។

សំណូមពរៈ ស្នើសុំតាមសេចក្តីថ្លែងការណ៍របស់ខ្លួនមានដូចខាងក្រោមៈ

១.ស្នើសុំផ្តាច់នីតិសង្វាសពីចុងចម្លើយ ។

២.សុំទាមទារតែបំណុលដែលក្មួយឈ្មោះ [redacted] ធារី បានខ្ចីប្រាក់ចំនួន២,០០០,០០០ (ពីរលាន) រៀល។

៣.សុំទាមទារប្រាក់ដែលប្អូនឈ្មោះ [redacted] លន់ បានខ្ចីចំនួន៧០០.០០០ (ចិតសិបម៉ឺន) រៀល ដែលជាព្រទ្យសម្បត្តិរួមរបស់ពួកខ្លួន ។

៤.និងសុំទាមទារប្រាក់ពីចុងចម្លើយបន្ថែមចំនួន ៥០០$ (ប្រាំរយដុល្លារ) ទឹកប្រាក់នេះប្រគល់ឱ្យមករូបខ្លួន នៅពេលសាលក្រមចូលជាស្ថាពរ។

៥.ប្រគល់ដីលំនៅដ្ឋាន ទំហំ២៧០៥ម² ស្ថិតនៅភូមិស្រែស្ប៉ូវ ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ វិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ ១០០៤០៣០៤-០០៩៣ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៤ របស់មន្ទីររៀបចំដែនដីនគររូបនីយកម្ម សំណង់ និងសុរិយោដីខេត្តក្រចេះ ដើមចោទឯកភាពឱ្យទៅចុងចម្លើយជាអ្នកកាន់កាប់ធ្វើជាកម្មសិទ្ធិ។

**១.សេចក្តីថ្លែងការណ៍របស់ចុងចម្លើយ**

ចុងចម្លើយដើមចោទឈ្មោះ [redacted] សំអាន និង មានមេធាវីតំណាងដោយអាណត្តិ លោក [redacted] បានធ្វើការអះអាងថាៈ រូបខ្លួនពិតជាបានរៀបអាពាហ៍ពិពាហ៍នៅថ្ងៃមិនចាំ ខែមករា ឆ្នាំ១៩៩១ ជាមួយឈ្មោះ [redacted] ជ័យ នៅភូមិកំពង់ស្វាយ ឃុំកំពង់ត្របែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង និងបានទៅចុះសំបុត្រអាពាហ៍ពិពាហ៍លេខ ១២៧ ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៧ នៅមន្ត្រីអាត្រានុកូលដ្ឋានសង្កាត់កំពង់លាវ ប្រាកដមែន។

-ចំពោះកូនគ្មានទេ។

ការរួមរស់ជាមួយគ្នាពីមុនកន្លងមក មិនដែលមានទំនាស់ទេ លុះដល់ក្នុងឆ្នាំ១៩៩៥ ប្តីរូបខ្លួនគាត់មានស្រីថ្មីក៏កើតមានភាពរកាំរកូស និងគ្នារហូតមក។

តបទៅនឹងសេចក្តីថ្លែងការណ៍របស់ដើមចោទខាងលើ រូបខ្លួនសុខចិត្តឯកភាពតាមការស្នើសុំរបស់ដើមចោទគ្រប់ចំណុច ។

**១.៥. ចំណុចវិវាទៈ**

-តើការប្តឹងសុំផ្តាច់សមគ្គសង្វាសរបស់ដើមចោទ ពិតជាមានមូលហេតុត្រឹមត្រូវដែរឬទេ?

## ២.ផ្នែកសំអាងហេតុ

**ក.ចំណុចស្ដីពីបណ្ដឹងសុំផ្ដាច់សមគ្គសង្វាស:**

២.១. តាមសេចក្ដីថ្លែងការណ៍របស់ដើមចោទ ក៏ដូចជាតាមសេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍លេខ ១២៧ សៀវភៅអាពាហ៍ពិពាហ៍លេខ ០៣/២០១៧ ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៧ របស់មន្ត្រីអត្រានុកូលដ្ឋានសង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង ឃើញថា គូភាគីបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីជាតិ និង បានប្ដឹងចុះសំបុត្រអាពាហ៍ពិពាហ៍ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានសង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង។ ដូចនេះ គូភាគីពិតជាមានចំណងអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ប្រាកដមែន។

២.៣.តាមការអះអាងរបស់ភាគីដើមចោទថា មូលហេតុដែលខ្លួនប្ដឹងសុំផ្ដាច់សមគ្គសង្វាសពីចុងចម្លើយ ដោយមូលហេតុថា មិនចុះសម្រុងដោយ ប្រើពាក្យសំដីអសរស់ ដេរបណ្ដេញខ្លួនចុះចេញពីផ្ទះ និងធ្លាប់ប្ដឹងរូបខ្លួន ដែលជាហេតុធ្វើឲ្យអស់មនោសញ្ចេតនាមិនអាចរួចរស់ជាមួយគ្នាតទៅទៀតបាន។

ភាគីដើមចោទក៏បានប្ដឹងសុំបែងចែកទ្រព្យសម្បត្តិរួមមាន៖

-ដីលំនៅដ្ឋាន (រស់នៅសព្វថ្ងៃ) មានទំហំ៦៣០ ម$^2$ និងមានព្រំប្រទល់ជាប់ ខាងកើតជាប់ដីឈ្មោះ [redacted] ប៊ុនណាត ខាងលិចជាប់ដីឈ្មោះ [redacted] សារុធ ខាងជើងជាប់ថ្នល់ និងខាងត្បូងមិនស្គាល់ឈ្មោះ។

ដីនេះស្ថិតនៅភូមិ០៨ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង ដែលមានវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ ១៤១១០៣០៨-០០៤៣ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៦។

-ផ្ទះឈើ១ខ្នង ប្រកស៊ីប្រូ ទំហំ៦ម គុណនឹង ៨ម សាងសង់ស្ថិតនៅដីលំនៅដ្ឋានខាងលើ។

-ដីលំនៅដ្ឋានចំនួន៣កន្លែង នៅក្នុងខេត្តក្រចេះ ៖

+ដីលំនៅដ្ឋាន (ប្លង់រឹង) ទំហំ២៥ម គុណនឹង ៣០០ម (ដីទំនេរ) ស្ថិតនៅភូមិស្រែស្បូវ ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ។

+ដីភនថ្មីថ្នល់លំ (មានលិខិតបញ្ជាក់ភូមិឃុំ) ទំហំ ២៥ម គុណនឹង ៣០០ម ស្ថិតនៅភូមិស្រែស្បូវ ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ។

+ដីភនថ្មីថ្នល់លំ (មានលិខិតបញ្ជាក់ភូមិឃុំ) ទំហំ ៧៥ម គុណនឹង ៣០០ម ស្ថិតនៅភូមិស្រែស្បូវ ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ។

ទាមទារបែងចែកប្រាក់ខែរបស់ខ្លួនដែលប្រពន្ធឈ្មោះ [redacted] សំអាន ជាអ្នកបើកយក និងប្រាក់ចំណូលផ្សេងៗទៀត រួមមាន៖



Scanned with CamScanner

-ប្រាក់ខែខ្លួនគិតចាប់ពីឆ្នាំ២០១០ រហូតដល់ឆ្នាំ២០១៨ មានរយៈពេល៨ឆ្នាំ ដោយក្នុង ១ឆ្នាំ ទឹកប្រាក់គិតជាមធ្យមចំនួន ២៤០០ ដុល្លាសរុបជាទឹកប្រាក់ចំនួន ១៩២០០ ដុល្លា ។

-ប្រាក់ចំណូលផាស៊ីម៉ូតូបានធ្វើនៅឆ្នាំ២០១៨ ទឹកប្រាក់ទទួលបានបន្ទាប់ពីរការទូទាត់រួចមានចំនួន១,០០០,០០០ (មួយលាន) រៀល ក្នុង១ខែ សរុបទឹកប្រាក់ទាំងអស់ចំនួន ១២,០០០,០០០ (ដប់ពីរលាន) រៀល។ ប៉ុន្តែមុនរៀបអាពាហ៍ពិពាហ៍រូបខ្លួនមានទ្រព្យសម្បត្តិផ្ទាល់ខ្លួន ចំនួន៥ដី ដែលខ្លួនបានមកឱ្យប្រពន្ធក្នុងការទិញដីនិងធ្វើផ្ទះ ។

២.៤. ប៉ុន្តែនៅក្នុងដំណាក់កាលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី២ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២០ ភាគីដើមចោទបានសុំធ្វើការលះបង់ការទាមទារនេះវិញ ដោយក្នុងពេលនេះដើមចោទសុំទាមទារតែបំណុលដែលក្មួយឈ្មោះ [redacted] ធារី បានខ្ចីប្រាក់ចំនួន២.០០០.០០០ (ពីរលាន) រៀល និងប្អូនឈ្មោះ [redacted] លន់ បានខ្ចីប្រាក់ចំនួន៧០០.០០០ (ចិតសិបម៉ឺន) រៀល ដែលជាទ្រព្យសម្បត្តិរួមរបស់ពួកខ្លួននោះ រូបខ្លួនសុំធ្វើការទាមទារ និង សុំទាមទារប្រាក់ពីចុងចម្លើយបន្ថែមចំនួន ៥០០$ (ប្រាំរយដុល្លា) ទឹកប្រាក់នេះប្រគល់ឱ្យមករូបខ្លួន នៅពេលសាលក្រមចូលជាស្ថាពរ ។ ដោយឡែក ដីលំនៅដ្ឋាន (រស់នៅសព្វថ្ងៃ) មានទំហំ៦៣០ ម៉ែត្រការ៉េ និងមានព្រំប្រទល់ជាប់ ខាងកើតជាប់ដីឈ្មោះ [redacted] ប៊ុនណាត ខាងលិចជាប់ដីឈ្មោះ [redacted] សាវុធ ខាងជើងជាប់ថ្នល់ និងខាងត្បូងមិនស្គាល់ឈ្មោះ ។

ដីនេះស្ថិតនៅភូមិ០៨ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង ដែលមានវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ ១៤១១០៣០៨-០០៤៣ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៦ ។

-ផ្ទះឈើ១ខ្នង ប្រកស៊ីប្រូ ទំហំ៦ម គុណនឹង ៨ម សាងសង់ស្ថិតនៅដីលំនៅដ្ឋានខាងលើ ដើមចោទឯកភាពឱ្យទៅចុងចម្លើយជាអ្នកកាន់កាប់ធ្វើជាកម្មសិទ្ធិ។

-ចំពោះដីលំនៅដ្ឋាន ទំហំ២៧០៥ម² ស្ថិតនៅភូមិស្រែស្បូវ ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ វិញ្ញាបនបត្រសម្គាល់អចនវត្ថុលេខ ១០០៤០៣០៤-០០៩៣ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៤ របស់មន្ទីររៀបចំដែនដីនគររូបណីយកម្ម សំណង់ និងសុរិយោដីខេត្តក្រចេះ ដើមចោទឯកភាពឱ្យទៅចុងចម្លើយជាអ្នកកាន់កាប់ធ្វើជាកម្មសិទ្ធិ ។

២.៥. យោងតាមការអះអាងរបស់ដើមចោទខាងលើ ពិតជាស្តែងឲ្យឃើញថា ចំណងអាពាហ៍ពិពាហ៍របស់គូភាគីពិតជាឈានដល់ចំណុចត្រូវបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិសន្ធានបានឡើយ ទោះបីជាតុលាការបានព្យាយាមធ្វើការផ្សះផ្សាយ៉ាងណាក៏ដោយ ក៏ភាគីដើមចោទមិនអាចសុះជាបានឡើយ ដូច្នេះគប្បីតុលាការពិចារណាដោយផ្អែកតាមមាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី ។

ខ.ចំណុចស្តីពីអំណាចមេធាៈ គ្មាន

គ.ចំណុចស្តីអំពីការបែងចែកទ្រព្យសម្បត្តិ:

ដើមចោទនិងចុងចម្លើយបានឯកភាពគ្នាចំពោះទ្រព្យសម្បត្តិរួមដូចខាងក្រោម:

-បំណុលដែលក្មួយឈ្មោះ [redacted]ធារី បានខ្ចីប្រាក់ចំនួន២,០០០,០០០ (ពីរលាន) រៀល ឱ្យទៅដើមចោទ។

-សុំទាមទារប្រាក់ដែលប្អូនឈ្មោះ [redacted] លន់ បានខ្ចីចំនួន៧០០.០០០ (ចិតសិបម៉ឺន) រៀល ឱ្យទៅដើមចោទ ។

-និងសុំទាមទារប្រាក់ពីចុងចម្លើយបន្ថែមចំនួន ៥០០$ (ប្រាំរយដុល្លារ) ទឹកប្រាក់នេះ ប្រគល់ឱ្យមកដើមចោទ នៅពេលសាលក្រមចូលជាស្ថាពរ។

- ប្រគល់ដីលំនៅដ្ឋាន (រស់នៅសព្វថ្ងៃ) មានទំហំ៦៣០ ម² និងមានព្រំប្រទល់ជាប់ ខាងកើតជាប់ដីឈ្មោះ [redacted]ប៊ុនណាត ខាងលិចជាប់ដីឈ្មោះ [redacted] សារុធ ខាងជើងជាប់ថ្នល់ និងខាងត្បូងមិនស្គាល់ឈ្មោះ ។

ដីនេះស្ថិតនៅភូមិ៨ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង ដែលមានវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ ១៤១១០៣០៨-០០៤៣ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៦ ឲ្យទៅឈ្មោះ [redacted] សំអាន ជាចុងចម្លើយ ជាអ្នកកាន់កាប់ធ្វើជាកម្មសិទ្ធិ។

-ប្រគល់ផ្ទះឈើ១ខ្នង ប្រកស៊ីប្រូ ទំហំ៦ម៉ែត្រ គុណនឹង ៨ម៉ែត្រ សាងសង់ស្ថិតនៅដីលំនៅដ្ឋានខាងលើឲ្យទៅឈ្មោះ [redacted] សំអាន ជាចុងចម្លើយ ជាអ្នកកាន់កាប់ធ្វើជាកម្មសិទ្ធិ។

-ប្រគល់ដីលំនៅដ្ឋាន ទំហំ២៧០៥ម៉ែត្រការ៉េ ស្ថិតនៅភូមិស្រែស្បូវ ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ វិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ ១០០៤០៣០៤-០០៩៣ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៤ របស់មន្ទីររៀបចំដែនដីនគររូបនីយកម្ម សំណង់ និងសុរិយោដីខេត្តក្រចេះ ដើមចោទឯកភាពឱ្យទៅចុងចម្លើយជាអ្នកកាន់កាប់ធ្វើជាកម្មសិទ្ធិ។

ឃ.សេចក្តីសន្និដ្ឋាន:

២.៦. រាល់ចំណុចដូចបានចង្អុលបង្ហាញខាងលើ បញ្ជាក់ឲ្យឃើញថា អង្គហេតុជាមូលដ្ឋាននៃការទាមទាររបស់ដើមចោទពិតជាមានអត្ថិភាពប្រាកដមែន រីឯចំណុចស្តីពី ការបែងចែកទ្រព្យសម្បត្តិរួមក៏ត្រូវបានគូភាគីឯកភាពគ្នារួចរាល់ហើយដែរ ដូច្នេះគប្បីតុលាការលើកយកមកពិចារណាធ្វើវិនិច្ឆ័យ។

ខ.អំពីប្រាក់ប្រដាប់ក្តី:

២.៧. ចំពោះប្រាក់ប្រដាប់ក្តីត្រូវអនុវត្តតាមមាត្រា៦៤ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## ៣.សេចក្តីសម្រេចបញ្ចប់

៣.១.ទទួលស្គាល់ការទាមទាររបស់ដើមចោទឈ្មោះ [redacted] ជ័យ តាមពាក្យបណ្តឹង ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០២០ ដោយបង្គាប់ថា៖

### ក.ចំណាដ់អាពាហ៍ពិពាហ៍:

បង្គាប់ឲ្យដាច់សមគ្គសង្វាសពីគ្នាជាប្តីប្រពន្ធរវាងដើមចោទឈ្មោះ [redacted] ជ័យ និង ចុងចម្លើយឈ្មោះ [redacted] សំអាន ចាប់ពីថ្ងៃនេះតទៅ។

### ១.បែងចែកទ្រព្យសម្បត្តិរួម:

១-ប្រគល់ទ្រព្យសម្បត្តិរួមមាន:

-ប្រគល់ប្រាក់បំណុលដែលក្មួយឈ្មោះ [redacted] ធារី បានខ្ចីចំនួន២,០០០,០០០ (ពីរលាន) រៀល ឱ្យទៅឈ្មោះ [redacted] ជ័យ ជាដើមចោទ តាមការព្រមព្រៀង។

- ប្រគល់ប្រាក់ដែលប្អូនឈ្មោះ [redacted] លន់ បានខ្ចីចំនួន៧០០.០០០ (ចិតសិបម៉ឺន) រៀលឱ្យទៅឈ្មោះ [redacted] ជ័យ ជាដើមចោទ តាមការព្រមព្រៀង។

-បង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] សំអាន ប្រគល់ប្រាក់បន្ថែមចំនួន ៩០០$ (ប្រាំរយដុល្លារ) ឱ្យទៅឈ្មោះ [redacted] ជ័យ ជាដើមចោទ ទឹកប្រាក់នេះប្រគល់ឱ្យមកដើមចោទ នៅពេលសាលក្រមចូលជាស្ថាពរ តាមការព្រមព្រៀង។

២-ប្រគល់ទ្រព្យសម្បត្តិរួមមាន:

- ដីលំនៅដ្ឋាន (រស់នៅសព្វថ្ងៃ) មានទំហំ៦៣០ ម² និងមានព្រំប្រទល់ជាប់ ខាងកើតជាប់ដីឈ្មោះ [redacted] ប៊ុនណាត ខាងលិចជាប់ដីឈ្មោះ [redacted] សារុធ ខាងជើងជាប់ថ្នល់ និងខាងត្បូងមិនស្គាល់ឈ្មោះ។

ដីនេះស្ថិតនៅភូមិ៨ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង ដែលមានវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ ១៤១១០៣០៨-០០៤៣ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៦ ឲ្យទៅឈ្មោះ [redacted] សំអាន ជាចុងចម្លើយ តាមការព្រមព្រៀង។

-ផ្ទះឈើ១ខ្នង ប្រកស៊ីប្រូ ទំហំ៦ម គុណនឹង ៨ម សាងសង់ស្ថិតនៅដីលំនៅដ្ឋានខាងលើឲ្យទៅឈ្មោះ [redacted] សំអាន ជាចុងចម្លើយ តាមការព្រមព្រៀង។។

-ប្រគល់ដីលំនៅដ្ឋាន ទំហំ២៧០៥ម² ស្ថិតនៅភូមិស្រែស្បូវ ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ វិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ ១០០៤០៣០៤-០០៩៣ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៤ របស់មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តក្រចេះ ឱ្យទៅឈ្មោះ [redacted] សំអាន ជាចុងចម្លើយ ជាអ្នកកាន់កាប់ធ្វើជាកម្មសិទ្ធិ តាមការព្រមព្រៀង។



Scanned with CamScanner

៣.២.ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ភាគីដើមចោទ។

សាលក្រមនេះបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ និង ថ្ងៃប្រកាសសាលក្រម នៅថ្ងៃអង្គារ ៩កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស២៥៦៤ ត្រូវនឹងថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២០ ចំពោះមុខដើមចោទ និង ចុងចម្លើយ បើកផ្លូវប្ដឹងឧបាស្រ័យតាមកំណត់ច្បាប់។

ក្រឡាបញ្ជី

[redacted]

ចៅក្រមជំនុំជម្រះ

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ព្រៃវែង ថ្ងៃទី......ខែ......ឆ្នាំ ២០២០

ក្រឡាបញ្ជី

[redacted]